# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អគ្គលេខាធិការដ្ឋាន**

### របាយការណ៍ ស្តីពី សិក្ខាសាលាស្តីពីការផ្លាស់ប្តូរយោបល់រវាងភ្នាក់ងារអនុវត្តច្បាប់ និងសង្គមស៊ីវិល ទាក់ទងនឹងការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តកំពង់ចាម

ឆ្នាំពីរពាន់ប្រាំបួន ខែតុលា ថ្ងៃទីដប់ប្រាំ និងប្រាំដប់មួយ វេលាម៉ោងប្រាំបួនព្រឹក នៅសាលាជាតិកសិកម្មខេត្តកំពង់ចាម មានរៀបចំសិក្ខាសាលាមួយក្រោមអធិបតីភាពឯកឧត្តម **សួង លាងហៃ** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានការចូលរួមពីលោកស្រី **ខុង ស៊ុងអេង** អភិបាលរងខេត្ត និងជាតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិបាលខេត្តកំពង់ចាមដើម្បីពិភាក្សា ផ្លាស់ប្តូរយោបល់រវាងភ្នាក់ងារអ្នកអនុវត្តច្បាប់ និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការនៅខេត្តកំពង់ចាម ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់មកជាមួយ។

ជាកិច្ចចាប់ផ្តើមលោកស្រី **ខុង ស៊ុងអេង** អភិបាលរងខេត្តកំពង់ចាមបានស្វាគមន៍គណៈអធិបតី និងបានថ្លែងអំណរគុណឯកឧត្តមអគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងពិភាក្សាផ្លាស់ប្តូរយោបល់លើកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការរវាងភ្នាក់ងារអនុវត្តច្បាប់និងសង្គមស៊ីវិល ដើម្បីផ្តល់នូវព័ត៌មាននិងចែករំលែកនូវបទពិសោធន៍ផ្សេងៗដល់មន្ត្រីរបស់ស្ថាប័នជំនាញនានានៅតាមខេត្តឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀតអំពីការកែទម្រង់ច្បាប់ និងតុលាការ។ លោកស្រីបានស្នើឱ្យអង្គសិក្ខាសាលាពិភាក្សាផ្លាស់ប្តូរយោបល់ឱ្យបានផុសផុលអំពីបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការហើយសង្ឃឹមថា សហការីមកពីមន្ទីរ-ស្ថាប័នជំនាញផ្សេងៗជុំវិញខេត្តនឹងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់នេះ និងប្រើប្រាស់ឱកាសនេះឱ្យបានល្អដើម្បីបន្ថែមនូវការយល់ដឹងឱ្យកាន់តែប្រសើរថែមទៀតលើវិស័យកំណែទម្រង់ច្បាប់និងតុលាការ។ ជាមួយគ្នានេះដែរលោកស្រីបានបញ្ជាក់ ថាខេត្តកំពង់ចាមមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអនុវត្តសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការនិងបន្តនូវការគាំទ្រឱ្យបានខ្លាំងក្លា ដើម្បីអនុវត្តការងារនេះហើយសង្ឃឹមថាសកម្មភាពកំណែទម្រង់ផ្សេងៗរបស់ខេត្តកំពង់ចាម នឹងអាចច្របាច់បញ្ចូលទៅក្នុងផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការរបស់រាជរដ្ឋាភិបាល ដើម្បីជួយជំរុញការអនុវត្តន៍យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការអោយកាន់តែប្រសើរថែមទៀត។

ឯកឧត្តម **សួង លាងហៃ** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានលើកឡើងថាកំណែទម្រង់ច្បាប់ និងតុលាការជាសមាសធាតុសំខាន់មួយនៃអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលតាំងពី

នីតិកាលទី៣នៃរដ្ឋសភាមកក្នុងការផ្តោះទៅរកការកាត់បន្ថយភាពក្រីក្រ។ ជាបន្ទាប់ឯកឧត្តមបានរំលឹកអំពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលមានសមាសភាពចម្រុះមកពីអង្គការនីតិប្រតិបត្តិ និងតុលាការ អំពីការកសាងឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការដែលបានទទួលការអនុម័តនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ និងឯកសារស្តីពីកម្មវិធីសកម្មភាព អនុម័តនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ដោយគណៈរដ្ឋមន្ត្រី។

លោក **ជឹម ផេងស្រ៊ុយ** ប្រធានផ្នែកគម្រោងប័ណ្ណាសារនិងព័ត៌មានវិទ្យា នៃអគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានធ្វើបទបង្ហាញពីការអនុវត្ត និងភាពជឿនលឿននៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយបញ្ចាំងស្លាយតាមឯកសារដែលបានចែកជូន។

លោក **ម្លូច់ ឆ្លាម** ប្រធានសាលាដំបូងខេត្តកំពង់ចាមបានឡើងធ្វើបទបង្ហាញអំពីដំណើរការផ្លូវច្បាប់នៅក្នុងរឿងរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌ។ លោកបានជម្រាបជូនអង្គសិក្ខាសាលាអំពីប្រវត្តិនៃការបង្កើតតុលាការតាំងពីឆ្នាំ១៩៧៩ ពីរបបសាធារណរដ្ឋប្រជា-មានិតកម្ពុជា មករបបរដ្ឋកម្ពុជានិងព្រះរាជាណាចក្រកម្ពុជា ដោយលោកបានមានប្រសាសន៍ថាកាលនៅរដ្ឋកម្ពុជាតុលាការរបស់យើងមានតែពីរថ្នាក់ទេគឺតុលាការជាន់ទាប “តុលាការថ្នាក់ខេត្ត ” និងតុលាការជាន់ខ្ពស់ “តុលាការកំពូល ” គឺគ្មានសាលាឧទ្ធរណ៍ទេ ប៉ុន្តែអ្វីដែលលោកចង់លើកជូនអង្គសិក្ខាសាលាឱ្យបានជ្រាបនៅពេលនោះគឺថា ថ្វីត្បិតមានតែតុលាការខេត្តមែន ប៉ុន្តែយើងមានយុត្តិធម៌ថ្នាក់ស្រុក យុត្តិធម៌ថ្នាក់ឃុំដែលជួយដោះស្រាយវិវាទ ធ្វើឱ្យវិវាទដែលកើតឡើងក្នុងឃុំឬស្រុកត្រូវបានកាត់បន្ថយ ហើយសំណុំរឿងមួយចំនួនតែប៉ុណ្ណោះត្រូវបានបញ្ជូនមកតុលាការ។ បន្ទាប់ពីឆ្នាំ១៩៩៣ ក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសមកយើងមានរដ្ឋាភិបាលថ្មី មានរដ្ឋធម្មនុញ្ញថ្មី រចនាសម្ព័ន្ធស្ថាប័នតុលាការរបស់យើងនាពេលនោះមានបីថ្នាក់គឺ សាលាដំបូង សាលាឧទ្ធរណ៍ ដល់តុលាការកំពូល។ ប៉ុន្តែអ្វីដែលគួរឱ្យសោកស្តាយ គឺយុត្តិធម៌ថ្នាក់ស្រុកនិងថ្នាក់ឃុំត្រូវបានលុបចេញវិញ ដូច្នេះរឿងវិវាទបទល្មើសជាបទលហុ មជ្ឈិម និងបទឧក្រិដ្ឋត្រូវសម្រុកចូលមកតុលាការ។ សំណុំរឿងទាំងអស់ត្រូវប្រឈមមកតុលាការទាំងអស់ដើម្បីធ្វើការពិនិត្យ និងដោះស្រាយ រីឯមន្ត្រីតុលាការ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជីមានចំនួនកំណត់ធ្វើឱ្យសំណុំរឿងកើនឡើងលើសពីចំនួនចៅក្រម ដែលមិនអាចរ៉ាប់រងបាន។

ជាបន្តលោកបានលើកឡើងពីនីតិវិធីជំរះក្តីទាំងក្នុងរឿងរដ្ឋប្បវេណីនិងរឿងព្រហ្មទណ្ឌតាំងពីសាលាបូង សាលាឧទ្ធរណ៍ ដល់តុលាការកំពូល ជូនអង្គសិក្ខាសាលាបានយល់ជ្រួតជ្រាប និងលើកយកជម្រាបផងដែរនូវការរៀបចំផែនការយុទ្ធសាស្ត្ររបស់តុលាការគំរូខេត្តកំពង់ចាម ព្រមទាំងបានលើកយកនូវបញ្ហាប្រឈមផ្សេងៗរបស់តុលាការខេត្តកំពង់ចាមដែលមានជាអាទិ៍៖

-បញ្ហាខ្វះសម្ភារៈ និងថវិកា

-បញ្ហាធនធានមនុស្ស ខ្វះ “ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា”

-ចៅក្រមខេត្តកំពង់ចាមត្រូវទទួលបន្ទុកបំពេញបន្ថែមជាចៅក្រមជំរះក្តីជាក្រុមប្រឹក្សានៅខេត្តក្រចេះ និងស្ទឹងត្រែង ដោយសាខេត្តទាំងពីរនេះមានការខ្វះខាតចៅក្រមក្នុងការដំណើរការរឿងក្តីបទក្រិដ្ឋ “កាត់ក្តីជាក្រុមប្រឹក្សា” បញ្ហាមធ្យោបាយស្នាក់នៅសោហ៊ុយផ្សេងៗ ក្នុងពេលដំណើរការ។

-ខ្វះខាតមេធាវីការពារចំពោះបទល្មើសឧក្រិដ្ឋ

-ភាពខុសប្លែកគ្នាទាំងស្រុងចំពោះក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានអ្នកជំនាញការច្បាប់ជប៉ុនជួយតាក់តែងច្បាប់ថ្មីនេះ ដែលជាការពិបាកសម្រាប់ចៅក្រមចាស់ៗរបស់យើង ហើយមានពាក្យបច្ចេកទេសថ្មីៗដែលធ្វើឱ្យចៅក្រមរបស់ យើងខិតខំរៀនបណ្ដើរ និងអនុវត្តបណ្ដើរ។

-បញ្ហាប្រឈមក្នុងការអនុវត្តសាលក្រម សាលដីការតែងតែជួបនូវបញ្ហាផ្សេងៗ។

លោក **ជុំ សែនសុខ្ញា** ព្រះរាជអាជ្ញារងខេត្តបានធ្វើបទបង្ហាញ ពីតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងប្រភេទរឿងក្ដីព្រហ្មទណ្ឌដែលត្រូវបញ្ជូនមកអយ្យការ។ លោកបានលើកឡើងតួនាទីព្រះរាជអាជ្ញា ជាមួយមន្ត្រីនគរបាលយុត្តិធម៌ ដែលមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយគ្នា។ មន្ត្រីនគរបាលយុត្តិធម៌ គួរធ្វើកំណត់ហេតុអង្កេតនិងបញ្ជូនមកព្រះរាជអាជ្ញានៅពេលមានបទល្មើសជាក់ស្ដែង និងបទល្មើសមិនជាក់ស្ដែង លោកបានពន្យល់ជូនដល់អង្គសិក្ខាសាលាបានជ្រួតជ្រាបពីនីតិវិធី នៃការស៊ើបសួរ ការឆែកឆេរ ការឃុំខ្លួន នីតិវិធីនៃការពន្យារពេលបទល្មើសលហុ មជ្ឈឹម និងបទល្មើសឧក្រិដ្ឋ និងអំពីនីតិវិធីនៃការឃាត់ខ្លួនដែលមានចែងក្នុងក្រមថ្មី។

សំណួរ ៖

លោក **លាខ សុទ៉ាត** តំណាងអង្គការក្រៅរដ្ឋាភិបាល លោកបានសួរថា តើមានកត្តាអ្វីខ្លះដែលអាចវាស់វែងភាពជឿនលឿនរីកចំរើនរបស់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដូចជាសូចនាករ និងការតាមដានជាដើម?

ឯកឧត្ដម **សួខ លាងហៃ** បានបញ្ជាក់ថា កម្មវិធីជាយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានសកម្មភាពលេខ ៧.៦.២ ស្ដីពីការតាមដានការធ្វើរបាយការណ៍ ព្រមទាំងមានក្រុមការងារបច្ចេកទេស ដែលមានការចូលរួមពីដៃគូអភិវឌ្ឍន៍បានប្រជុំជាទៀងទាត់រាល់ពីរខែម្ដង ធ្វើការពិភាក្សាពិនិត្យទៅលើសូចនាករតាមដានរួមទាំងដៃគូអភិវឌ្ឍន៍ ទាំងរដ្ឋាភិបាល ហើយមានក្រុមការងារមួយទៀតរបស់អគ្គលេខាធិការដ្ឋាន កំពុងរៀបចំផែនការអភិវឌ្ឍន៍ប្រព័ន្ធសូចនាករតាមដានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

លោកស្រីតំណាងអភិបាលស្រុកត្បូងឃ្មុំ បានលើកសំណួរចំនួនបីពាក់ព័ន្ធ៖

១-ការដោះស្រាយវិវាទដីធ្លី

២-វិវាទគ្រួសារ និងអាពាហ៍ពិពាហ៍

៣-អំពើហិង្សាក្នុងគ្រួសារ។

១-លោកស្រីបានលើកឡើងថា ចំពោះរឿងវិវាទដីធ្លីប្រជាពលរដ្ឋភាគច្រើនទទូចសុំឱ្យមានការដោះស្រាយនៅត្រឹមថ្នាក់ឃុំ ឬថ្នាក់ស្រុកបានហើយ ទោះបីជាពួកគាត់ដឹងថាមិនអាចទៅរួចក៏ដោយ។

២-ចំពោះរឿងលែងលះគ្រួសារ ពួកគាត់មិនចង់អោយមានការដោះស្រាយនៅតុលាការទេ ដោយបានសំណូមពរទៅអាជ្ញាធរឱ្យដោះស្រាយត្រឹមថ្នាក់ឃុំឬស្រុក។ បញ្ហាការរស់នៅមិនចុះសម្រុងគ្នា ការទាមទារសងថ្លៃបណ្ណាការវិញជាដើម ថាតើមានវិធីសាស្ត្រដោះស្រាយយ៉ាងដូចម្ដេចសម្រាប់ថ្នាក់ឃុំ សូមឱ្យលោកប្រធានតុលាការជួយបំភ្លឺ ?

៣-បញ្ហាអំពើហិង្សាក្នុងគ្រួសារមានបង្ករបួសស្នាម នៅពេលដែលសមត្ថកិច្ចធ្វើកំណត់ហេតុអ្នកបង្ករបួសស្នាម បែរជាប្រពន្ធសុំអង្វរសមត្ថកិច្ច? ថាតើគួរយើងធ្វើរបៀបណា?

លោក **ម្លង់ ឆ្លាម** បានឆ្លើយបំភ្លឺថា ទាំងនេះជាផលវិបាករបស់សង្គមយើង ប្រជាពលរដ្ឋគាត់មិនទាន់យល់ជ្រួតជ្រាបពីច្បាប់ដូចជាបញ្ហាដីធ្លី លោកបានបញ្ជាក់ថា សូម្បីតែមនុស្សក៏មិនទាន់មានអត្តសញ្ញាណគ្រប់គ្នាផង។

ចំពោះបញ្ហាពាក់ព័ន្ធនឹងរឿងសងបណ្ណាការ លោកបានបញ្ជាក់ថានៅក្នុងផ្លូវច្បាប់មិនមានបង្គាប់អោយសងទេ ប៉ុន្តែអាចសងជាជម្ងឺចិត្ត ត្រង់ចំណុចនេះក៏ជាសមត្ថកិច្ចរបស់តុលាការដែរ។

ចំពោះរឿងបង្ករអំពើហិង្សាក្នុងគ្រួសារ លោកបញ្ជាក់ថា បើសិនជាមានបង្កររបួសស្នាមនោះគឺជាបទល្មើសព្រហ្មទណ្ឌ គឺត្រូវកសាងសំណុំរឿងបញ្ជូនមកតុលាការ។

លោកព្រះរាជអាជ្ញារងខេត្ត បានបញ្ជាក់បន្ថែមថាចំពោះអំពើហិង្សាក្នុងគ្រួសារ កាលណាវាយដំ បង្កជារបួសស្នាមនោះជាបទល្មើសព្រហ្មទណ្ឌ ចំណែកឯរឿងសុំដកពាក្យពីភាគីប្រព័ន្ធឬជនរងគ្រោះនោះ គ្រាន់តែជាការដកបណ្តឹងរដ្ឋប្បវេណី ចំណែកឯបណ្តឹង-អាជ្ញាគឺនៅរក្សាដដែល។ ដូច្នេះបញ្ហានេះគួរកសាងសំណុំរឿងបញ្ជូនមកតុលាការ ដើម្បីធ្វើឱ្យគាត់រាងចាល នេះបើតាមយោបល់របស់លោកផ្ទាល់។

សំណួរ ៖ ១-បញ្ហាជនល្មើសបង្កររបួសស្នាម "ក្រុមក្មេងទំនើង" វាយតប់គ្នាក្នុងពិធីបុណ្យ ធ្វើអោយមានរបួសស្នាមមានវត្ថុតាងកាំបិត ពូថៅ សួរថា ហេតុអ្វីបានជារឿងបង្ករបួសស្នាមត្រូវបានធ្វើការសម្រុះសម្រួលគ្នាហើយពុំត្រូវបានផ្តន្ទាទោសទៅវិញ?

២-ចំពោះបទល្មើសរំលោភសេពសន្ថវៈ ក៏មានបញ្ហាដូចគ្នារដែរ ព្រោះថាជនល្មើសមិនរាងចាល។

លោកព្រះរាជអាជ្ញារង ករណីនេះជាសំណងរដ្ឋប្បវេណី ប៉ុន្តែហេតុអ្វីអ្នកប្រព្រឹត្តបទល្មើសពុំត្រូវបានបញ្ជូនមកតុលាការ? លោកបានបញ្ជាក់ថា គ្រប់បទល្មើសព្រហ្មទណ្ឌត្រូវតែរាយការណ៍មកអយ្យការ ករណីខ្លះនៅឆ្ងាយហើយមន្ត្រីរបស់យើងពុំបានរាយ-ការណ៍មក តើអយ្យការធ្វើម្តេចនឹងដឹង? តាមផ្លូវច្បាប់មិនមែនមានសំណងហើយត្រូវបានរួចខ្លួននោះទេ។ លោកក៏បានប្រាប់នូវលេខទូរស័ព្ទ និងអ៊ីម៉ែលដើម្បីងាយស្រួលផ្តល់ព័ត៌មានផ្ទាល់ដល់ខាងអយ្យការគ្រប់ពេល និងទាន់ពេលវេលា។

លោក **ឈាង ស៊ូវ៉ាត** តំណាងអង្គការក្រៅរដ្ឋាភិបាល ធ្វើចំណាប់អារម្មណ៍ទាក់ទងពីភាពរីកចម្រើនជឿនទៅលើវិស័យច្បាប់ក្នុងរយៈកាលកន្លងមកដោយលោកបានលើកឡើងថា ក្នុងខេត្តកំពង់ចាមមានអង្គការក្រៅរដ្ឋាភិបាលប្រមាណជា៨០ កំពុងដំណើរការខ្លះលើវិស័យច្បាប់ កសិកម្ម សុខាភិបាល នេសាទ។ អង្គការអាដហុកធ្វើការលើវិស័យសិទ្ធិមនុស្ស ដែលពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌នេះតែម្តងព្រមជាមួយគ្នានេះ លោកបានលើកឡើងពីបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋដែលមិនបានយល់ដឹងពីច្បាប់ និងមានការភ័យខ្លាចក្នុងការទៅបំភ្លឺនៅតុលាការគឺ "ការធ្វើសាក្ខីកម្ម"។

ក្រុមប្រឹក្សាឃុំ បានស្នើសុំឱ្យលោកប្រធានសាលាដំបូងខេត្តបកស្រាយចំពោះការសម្របសម្រួលក្នុងរឿងរដ្ឋប្បវេណី ដូចជារឿងជេរទៅជេរមក រឿងប្រមាថជាដើម។ល។

លោកប្រធានតុលាការបានបញ្ជាក់ថា សំណុំរឿងសព្វថ្ងៃមានច្រើនណាស់ យើងត្រូវយល់នូវពាក្យសម្របសម្រួល និងផ្សះផ្សាគឺត្រូវទាមទារឱ្យអ្នកសម្របសម្រួលមានចំណេះដឹងខាងផ្លូវច្បាប់ មានអាយុចាស់ជាង ឬក៏យល់ដឹងជាងភាគី ហើយមានការគោរពនៅក្នុងមជ្ឈដ្ឋាននោះទើបគេស្តាប់។

សំណួរ៖

លោកតំណាងអង្គការ NGO បានលើកឡើងចំពោះបញ្ហារត់ការសំណុំរឿងផ្សេងៗ ដូចជាការក្លែងខ្លួនធ្វើជាមេធាវីជាដើម។

លោកប្រធានតុលាការបានបំភ្លឺថា ចំពោះរឿងឆ្នូកជេរសំណុំរឿង ឬក្លែងបន្លំផ្សេងៗ លោកថាពិតជាមានមែនមិនថាតែកំពង់ចាមទេ លោកប្រធានបានលើកឡើងថា នៅសាលាដំបូងភ្នំពេញមានការចាប់ដាក់គុកច្រើននាក់ហើយ សព្វថ្ងៃគ្មានបញ្ហានេះទៀតទេ។

លោកព្រះរាជអាជ្ញារងខេត្តបានបញ្ជាក់បន្ថែមថា ចំពោះរឿងរត់ការសំណុំរឿងផ្សេងៗ ឬក្លែងឆបោកថាអ្នកនេះ ឬអ្នកនោះ លោកក៏បានស្នើសុំឱ្យដាក់ពាក្យប្តឹងមកខាងអយ្យការដើម្បីចាត់ការ។

លោកតំណាងអង្គការ NGO បានស្នើឱ្យមាន៖

១-ការជជែកពិភាក្សាផ្លាស់ប្តូរយោបល់របៀបនេះអោយបានយ៉ាងហោចណាស់រយៈពេល ០៦ ខែ ម្តង ដូចអង្គសិក្ខាសាលាថ្ងៃនេះ

២-ការបើកវគ្គខ្លីៗអំពីច្បាប់ដល់ប្រជាពលរដ្ឋ

៣-ការផ្តល់លទ្ធភាពឱ្យអាជ្ញាធរឃុំសង្កាត់មានសិទ្ធិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចំពោះរឿងរដ្ឋប្បវេណីតូចតាច ឬបទលហុ រឿងលែងលះគ្រួសារជាដើម។

យោងតាមរបៀបវារៈនៅថ្ងៃបន្ទាប់គឺជាការពិភាក្សាតាមក្រុម (លទ្ធផលនៃការពិភាក្សាតាមក្រុមមានភ្ជាប់ជាមួយរបាយការណ៍នេះ )។

បន្ទាប់ពីក្រុមពិភាក្សាបានធ្វើរបាយការណ៍អំពីលទ្ធផល នៃការពិភាក្សាតាមក្រុមរួចមក លោកប្រធានតុលាការ និង លោកព្រះរាជអាជ្ញារង បានឆ្លើយបំភ្លឺជូនអង្គសិក្ខាសាលាឱ្យបានយល់ជ្រួតជ្រាបនូវបញ្ហាពាក់ព័ន្ធមួយចំនួន។ ជាបន្ទាប់ឯកឧត្តមប្រធានអង្គសិក្ខាសាលា បានធ្វើការបូកសរុបលទ្ធផលនៃអង្គសិក្ខាសាលារយៈពេលពីរថ្ងៃកន្លងមកនេះ ដោយវាយតម្លៃថា សិក្ខាសាលានៅខេត្តកំពង់ចាមនេះមានសារៈសំខាន់ណាស់ សម្រាប់ការពិនិត្យពិចារណាកែលំអ និងរុញច្រានកំណែទម្រង់ច្បាប់ និងតុលាការឱ្យមានសន្ទុះលឿនទៅមុខខ្លាំងថែមទៀត និងចំទិសដៅ។

មុននឹងបញ្ចប់ ឯកឧត្តមប្រធានបានថ្លែងអំណរអរគុណសាជាថ្មីចំពោះឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា មន្ត្រីរាជការមន្ទីរជុំវិញខេត្ត ព្រមទាំងអង្គការសង្គមស៊ីវិលទាំងអស់ ដែលបានចំណាយពេលវេលាចូលរួមក្នុងអង្គសិក្ខាសាលារយៈពេលពីរថ្ងៃនេះ និងបានប្រសិទ្ធិពរជ័យទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជូនដល់អង្គសិក្ខាសាលាទាំងមូល។

អង្គសិក្ខាសាលាបានចប់សព្វគ្រប់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោងដប់ពីរថ្ងៃត្រង់។

*រាជធានីភ្នំពេញ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩*

អ្នកធ្វើរបាយការណ៍

**បានឃើញ និងឯកភាព**

អគ្គលេខាធិការរង

ស៊ុន សិរីវុធ

សួង លាងហៃ

ការបែងចែកក្រុមពិភាក្សាទៅលើប្រធានបទ៖ បញ្ហាការប្រឈមចំពោះសិទ្ធិទទួលបានយុត្តិធម៌ពីតុលាការ (ការប្រឈមចំពោះការផ្តល់សេវា និងទទួលសេវាពីតុលាការ)ការផ្តល់ជាមតិយោបល់

ក្រុមទី១ ៖ មេឃុំចៅសង្កាត់

I។បញ្ហាប្រឈម

១-បញ្ហាពិបាកកំណត់បទល្មើសព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ឧទាហរណ៍ "ការជេរប្រមាថដោយមានកាំបិតព្រនង់ ប៉ុន្តែពុំបានវាយតប់ទេ"។

២-ការទៅរករឿងវាយគេមុន "វាយនឹងដៃ" ដល់ម្ខាងទៀតមានកំហឹងវាយតបវិញបណ្តាលឱ្យមានរបួសហូរឈាម អ្នកវាយតតបបែរជាមានទោសតែម្នាក់ឯង។

៣-ប្រជាពលរដ្ឋនៅតែមានបណ្តឹងទាមទារកេរ្តិ៍មុនឆ្នាំ ១៩៧៩។

៤-ក្រុមប្រឹក្សាឃុំមិនបានរៀនច្បាប់ ការយល់ដឹងនៅមានកំរិត។

៥-ការផ្សព្វផ្សាយច្បាប់មិនបានដល់មូលដ្ឋាន។

៦-តុលាការនៅឆ្ងាយ និងប្រជាពលរដ្ឋនៅឆ្ងាយគ្មានលទ្ធភាពមកដល់។

៧-ការចំណាយរឿងក្តីនៅតុលាការអស់ប្រាក់ច្រើន។

៨-អ្នកមានអំណាច និងអ្នកមានប្រាក់ច្រើឈ្នះក្តី។

៩-អំពើហឹង្សាក្នុងគ្រួសារ នគរបាលប៉ុស្តិ៍ច្រើនចាប់បញ្ជូនទៅអធិការស្រុកតែម្តងដោយគ្មានធ្វើការអប់រំសិន។

១០-វិធានការទប់ស្កាត់ជនជួញក្តី។

១១-សកម្មភាពក្មេងទំនើងកើតឡើង សមត្ថកិច្ចមានការយឺតយ៉ាវ។

១២-ដីការកោះហៅច្រើនហួសពេលកំណត់។

១៣-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ខាងសមត្ថកិច្ចច្រើនមិនអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់។

១៤-វិធានការ ការលក់ដូរ និងប្រើប្រាស់គ្រឿងញៀននៅមានភាពធូររលុង។

II.ការផ្តល់មតិ និងសំណូមពរ៖

១-សូមឱ្យមានការបណ្តុះបណ្តាលច្បាប់ដល់ក្រុមប្រឹក្សាឃុំសង្កាត់មានវគ្គខ្លីៗ ឬជាកាសែតខ្សែអាត់អំពីច្បាប់អោយឃុំចាក់ផ្សាយដល់មូលដ្ឋាន។

២-សុំអោយតុលាការពិចារណាលើការបំភ្លឺរបស់អាជ្ញាធរមូលដ្ឋានផង។

៣-បទល្មើសដូចគ្នា សុំអោយមានការកាត់ទោសដូចគ្នា។

៤-រឿងក្តីដល់តុលាការហើយ សុំកុំបង្វែទៅឃុំវិញ។

ក្រុមទី២ ៖ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន

I.បញ្ហាប្រឈម ៖

១-ប្រជាពលរដ្ឋមិនប៊ានផ្តល់សក្ខីកម្ម។

២-ភាពភ័យខ្លាចពីសុវត្ថិភាពផ្ទាល់ខ្លួន "និទណ្ឌភាព"។

៣-ប្រជាពលរដ្ឋពុំសូវមានការយល់ដឹងពីច្បាប់។

៤-ការចំណាយលើការប្ដឹងផ្ដល់អស់សាហ៊ុយច្រើន។

៥-សីលធម៌ធ្វើការនៅតុលាការ“ក្រុមសីលធម៌វិជ្ជាជីវៈ”។

៦-វិសមភាពចំពោះមុខច្បាប់។

៧-ខ្វះការផ្សព្វផ្សាយអំពីច្បាប់ដល់ប្រជាពលរដ្ឋ។

៨-ការទទួលបានដីការប្រញាប់ពីតុលាការមានការយឺតយ៉ាវ។

៩-ខ្វះការគាំទ្រជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួម។

១០-វិសមភាពនៃការទទួលព័ត៌មានពីតុលាការ។

១១-ការអនុវត្តសាលក្រមនៅមានចន្លោះ“មានអន្តរាគម៍ពីស្ថាប័នផ្សេងៗ”។

១២-ប្រជាពលរដ្ឋពិបាកក្នុងការរកតំណាង “ការចាប់ខ្លួនតំណាង“។

១៣-ការសហការរវាងអង្គការក្រៅរដ្ឋាភិបាក និងសមត្ថកិច្ចនៅមានកំរិត។

II. ការផ្ដល់មតិ និងសំណូមពរ ៖

១- សូមឱ្យមានក្រុមសីលធម៏សម្រាប់ស្ថាប័នតុលាការ ។

២- លើកកំពស់ការផ្សព្វផ្សាយ និងការបណ្ដុះបណ្ដាលអំពីច្បាប់ដល់មហាជន និងអ្នកអនុវត្តច្បាប់។

៣-សូមកុំឱ្យមានការជ្រៀតជ្រែកក្នុងប្រព័ន្ធតុលាការ។

៤-សូមឱ្យមានសមភាពចំពោះមុខច្បាប់។

៥-ជំរុញឱ្យមានក្រុមសីលធម៏វិជ្ជាជីវៈរបស់ចៅក្រម។

៦-ជំរុញឱ្យអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ។

៧-សូមឱ្យមានវេទិការពិគ្រោះយោបល់ឱ្យបាន ៦ខែម្ដងជាមួយនឹងអ្នកពាក់ព័ន្ធ។

៨-សូមឱ្យមានការទទួលស្គាល់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

៩-សូមឱ្យមានកិច្ចសហការល្អរវាងអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធអោយបានទូលំទូលាយ។

១០-សូមអោយមានការគ្រប់គ្រងអាវុធជាតិផ្ទុះឱ្យបានម៉ឺងម៉ាត់។

១១-សូមឱ្យមានការចាត់ការរឿងក្ដីអោយបានទាន់ពេលវេលា។

ក្រុមទី៣ ៖ តុលាការ នឹងអយ្យការ

I.បញ្ហាប្រឈម ៖

១-ក្នុងការដោះស្រាយរឿងក្ដីមានការលំបាក និងស្មុគស្មាញ ដោយហេតុថា ប្រព័ន្ធតុលាការសព្វថ្ងៃមានភាពខ្វះខាតសម្ភារៈបច្ចេកទេសទំនើប “កោលស្សវិច្ច័យ”។

២-មធ្យោបាយ និងថវិកាក្នុងការចុះអង្កេត។

៣-កង្វះខាតមេធាវី។

៤-ការអនុវត្តសាលក្រមមានការលំបាក។

៥-កង្វះខាតជំនាញ អ្នកបកប្រែភាសា។

៦-កង្វះខាតពីស្ថាប័នផ្សេងៗ ក្នុងការសហការអនុវត្តនីតិវិធី។

ក្រុមទី៥៖ មន្ទីរជុំវិញខេត្ត និងពន្ធនាគារ

I.បញ្ហាប្រឈម៖

១-ការយល់ដឹងពីច្បាប់របស់ប្រជាពលរដ្ឋនៅមានកំរិតទាប។

២-លទ្ធភាពផ្សព្វផ្សាយច្បាប់មិនទាន់បានទូលំទូលាយ។

៣-ចំណេះដឹងទូទៅ នឹងឆន្ទៈចូលរួមរៀនសូត្រពីច្បាប់របស់ប្រជាពលរដ្ឋនៅមានកំរិត។

៤-ភាពក្រីក្រជាឧបសគ្គចំបងក្នុងការទទួលសេវាច្បាប់ និងយុត្តិធម៌។

៥-ការញុះញង់បំផុសពីអ្នកនយោបាយជ្រុលនិយម។

៦-ភាពមិនប្រក្រតីក្នុងប្រព័ន្ធអនុវត្តច្បាប់ "តុលាការ" ធ្វើអោយប្រជាពលរដ្ឋខ្វះការជឿជាក់ និងភាពកក់ក្តៅ។

II. ការផ្តល់មតិ និងសំណូមពរ ៖

១-គួរតែបង្កើនលទ្ធភាព និងសមត្ថភាពដល់ស្ថាប័ន និងមន្ត្រីផ្សព្វផ្សាយច្បាប់ព្រមទាំងពង្រីកយន្តការឱ្យបានសមស្រប និងរស់រវើក ដើម្បីបញ្ជ្រាបអំពីវិស័យច្បាប់ដល់ប្រជាពលរដ្ឋ។

២-គួរតែជំរុញការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការអោយបានទូលំទូលាយនៅតាមបណ្តាស្រុក ដើម្បីបង្ករភាពងាយស្រួលដល់ ប្រជាពលរដ្ឋ។

៣-កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការអោយបានស៊ីជម្រៅ ដើម្បីបង្កើនការជឿជាក់ និងកក់ក្តៅពីសំណាក់ប្រជាពលរដ្ឋ។

ក្រុមទី៦៖ អធិការនគរបាល និងអធិការរងនគរបាលស្រុក

I.បញ្ហាប្រឈម៖

១- ប្រជាពលរដ្ឋភាគច្រើនពុំយល់ដឹងពីច្បាប់ ។

២- ខ្វះខាតសម្ភារៈបច្ចេកទេស មធ្យោបាយ ថវិកា។

៣-ការយល់ដឹងរបស់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលនៅមានកំរិត។

៤-ជនល្មើសផ្តន្ទាទោសហើយមិនរាងចាល។

៥-ពេលមានបទល្មើសកើតឡើងពិបាករកសាក្សី "ក្នុងការធ្វើសាក្ខីកម្ម"។

៦-ការទទួលព័ត៌មានពុំទាន់ពេលវេលា។

៧-ការអនុវត្ត ចលនាប្រជាការពាររបស់ប្រជាពលរដ្ឋមនៅមានកំរិត។

II. ការផ្តល់មតិ និងសំណូមពរ ៖

១-ការបណ្តុះបណ្តាលដល់មន្ត្រីអ្នកអនុវត្តច្បាប់។

២-ការផ្សព្វផ្សាយច្បាប់អោយបានទូលំទូលាយដល់ប្រជាពលរដ្ឋ។

៣-ថវិកា សម្ភារៈបច្ចេកទេស មធ្យោបាយដើម្បីបម្រើកិច្ចការជំនាញ។

ក្រុមទី៧ ៖នាយប៉ុស្តិ៍រដ្ឋបាលឃុំ-សង្កាត់

I.បញ្ហាប្រឈមៈ

១-បញ្ហាមេធាវីការពារកូនក្តី៖

-នៅពេលមេធាវីធានាជនសង្ស័យឱ្យនៅក្រៅឃុំ ជនសង្ស័យប្រព្រឹត្តបទល្មើបន្តទៀត។

២-បញ្ហាឃាត់ខ្លួនបទល្មើសជាក់ស្តែង-មានការអន្តរាគមន៍ពីថ្នាក់លើឱ្យដោះលែង។

៣-គ្មានទីតាំងប៉ុស្តិ៍រដ្ឋបាល និងសម្ភារៈប្រើប្រាស់

៤- បញ្ហាមនុស្សស្លាប់ មនុស្សឃាត

- ខ្វះស្ថាប័នពាក់ព័ន្ធចូលរួម

- មានការយឺតយ៉ាវ។

II. ការផ្តល់មតិ និងសំណូមពរ ៖ គ្មាន

ក្រុមទី៨ ៖ អភិបាលស្រុក និងអភិបាលរងស្រុក

I.បញ្ហាប្រឈមៈ"ការប្រឈមចំពោះសិទ្ធិទទួលបានយុត្តិធម៌"

១-ច្បាប់ពុំទាន់គ្រប់គ្រាន់ ...........

២-ការផ្សព្វផ្សាយច្បាប់មិនទាន់បានស៊ីជំម្រៅ ។

៣- ប្រជាពលរដ្ឋគ្មានជំនឿទុកចិត្តលើស្ថាប័នតុលាការអនុវត្តច្បាប់។

៤-មន្ត្រីអ្នកអនុវត្តច្បាប់នៅមានកំរិត គ្មានតម្លាភាព។

៥-ប្រជាពលរដ្ឋពុំយល់ដឹងពីច្បាប់ គាត់ប្រើទម្លាប់។

៦-ប្រជាពលរដ្ឋខ្វះចំណេះដឹង-ភាពក្រីក្រ ....

II. ការផ្តល់មតិ និងសំណូមពរ ៖

១-មានបើកវគ្គខ្លីៗពីច្បាប់ ដល់ស្ថាប័នរដ្ឋ និងប្រជាពលរដ្ឋ។

២-ផ្តល់លទ្ធភាពឱ្យអាជ្ញាធរស្រុក ឃុំ ភូមិ មានលទ្ធភាពដោះស្រាយវិវាទតូចតាច " រដ្ឋប្បវេណី"។

៣-សុំអោយមានមន្ត្រីយុត្តិធម៌ថ្នាក់ស្រុក-ក្រុង។

***ចំពោះការបែងចែកក្រុមពិភាក្សានៅខេត្តកំពង់ចាមនេះមានតែប្រាំពីក្រុមដោយ ក្រុមពិភាក្សាទី៥៖ កងរាជអាវុធហត្ថ មានសមាជិក តែពីរនាក់ត្រូវបញ្ចូលក្នុង ក្រុមពិភាក្សាទី៦៖ អធិការនគរបាល និងអធិការរងនគរបាលស្រុក៕